# បានកែសម្រួលតាមស្មារតីនៃកិច្ចប្រជុំផ្ទៃក្នុង ក្រុមប្រឹក្សាអ្នកច្បាប់ថ្ងៃទី៖

១. ០៧/ ០៣/១១(១៥.០០.១៧.០០)
២. ២៤/ ០៣/១១(៨.៣០.១១.០០)
៣. ០៤/០៧/១១(៨.៣០.១១.០០)
៤. ០៧/០៧/១១(៨.៣០.១០.០០)
៥. ១៤/០/.១១(៨.៣០.១០.០០)
៦. ១៨/០៧/១១(៨.៣០.១១.០០)
៧. ២៦/០៧/១១(៨.៣០.១១.០០)
៨. ០២/០៨/១១(៨.៣០.១១.០០)
៩. ១២.០៨.១១(៨.៣០.១១.០០)
១០. ១៧/០៨/១១(៨.៣០.១១.០០)
១១. ៨/០៩/១១(៨.៣០.១១.០០)
១២. ២០/០៩/១១(៨.៣០.១១.០០)
១៣. ១៨/១០/១១(៨.៣០.១១.០០)
១៤. ២០/១០/១១(៨.៣០.១១.០០)

សេចក្ដីព្រាង

# ច្បាប់
# ស្ដីពី
# ការរៀបចំអង្គការតុលាការ និងអយ្យការ

# ច្បាប់
# ស្តីពី
# ការចាត់តាំងអង្គការតុលាការ និងអយ្យការ
## ជំពូកទី១
## បទបញ្ញត្តិទូទៅ

*(បង្កើត ៣ មាត្រាទៀត ដែលនិយាយពីគោលបំណង គោលដៅ និងវិសាលភាព)

### មាត្រា ១..

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចត្រូវប្រគល់ឲ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ដែលត្រូវរៀបចំបង្កើតឡើងដោយច្បាប់នេះ។

*(បង្កើត ១ មាត្រាទៀត ដែលនិយាយពីអយ្យការ)

### មាត្រា ២..

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជាពលរដ្ឋខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ដោយតុលាការដែលមានលំដាប់ដូចតទៅ៖

-តុលាការកំពូល

-សាលាឧទ្ធរណ៍

-សាលាដំបូង។

តុលាការយោធាជាតុលាការដោយឡែកដែលមានថ្នាក់ស្មើនឹងសាលាដំបូង។

ក្រៅពីតុលាការដែលបានរៀបរាប់ខាងលើនេះ តុលាការពិសេស ឬតុលាការវិសាមញ្ញអាចត្រូវបានបង្កើតឡើងដោយច្បាប់ ដោយឡែកយោងតាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង។

ប្រធានតុលាការនីមួយៗ មានអំណាចឋានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានសភាទាំងអស់នៃតុលាការនោះ។ ប្រធានសភានីមួយៗមានអំណាចឋានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក។

### មាត្រា ៣..

មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារៈកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។

មានតែសាលាជម្រះក្តីដែលមានចែងដោយច្បាប់ប៉ុណ្ណោះ ទើបអាចប្រកាសសេចក្តីសម្រេចសេចក្តីបាន។

មាត្រា ៤..

មានតែអង្គអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។

តំណាងអយ្យការត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ។

ក្រៅពីរឿងក្តីព្រហ្មទណ្ឌ ក្នុងករណីដែលយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តំណាងអង្គអយ្យការអាចចូលរួមក្នុងនីតិវិធី និងផ្តល់យោបល់ដោយអនុលោមតាមបញ្ញត្តិនៃនីតិវិធីជាធរមាន។ (សូមទុកស្រាវជ្រាវឡើងវិញ ចំពោះបញ្ហាតំណាងអង្គអយ្យការក្នុងរឿងរដ្ឋប្បវេណី)

មាត្រា ៥..

នៅគ្រប់តុលាការ និងអយ្យការ មានការិយាល័យក្រឡាបបញ្ជីជាជំនួយការ។ ក្រឡាបបញ្ជីជួយចៅក្រម នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។

តួនាទី និងមុខងាររបស់ក្រឡាបញ្ជីត្រូវកំណត់លក្ខន្តិកៈក្រឡាបបញ្ជី។

## ជំពូកទី២

## សាលាដំបូង និងអយ្យការអមសាលាដំបូង

## ផ្នែកទី១ សាលាដំបូង

## អនុផ្នែកទី ១ ការរៀបចំ និងការប្រព្រឹត្តទៅ

មាត្រា ៦..

សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ដំបូងដែលមានទីតាំងនៅរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៧..

-សមាភាពសាលាដំបូងរួមមានៈ

-ប្រធាន

-អនុប្រធាន

-ចៅក្រម

-នាយក្រឡាបញ្ជី

-ក្រឡាបញ្ជីនិង

-មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបានបំរើការនៅសាលាដំបូង។

មាត្រា ៨..

ត្រូវបង្កើតលេខាធិការដ្ឋានរដ្ឋបាលសម្រាប់សាលាដំបូង ដែលទទួលបន្ទុកការងារបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មាត្រា ៩..

-សាលាដំបូងមានសភា ជាអាទិ៍៖

-សភារដ្ឋប្បវេណី

-សភាព្រហ្មទណ្ឌ

-សភារដ្ឋបាល

-សភាពាណិជ្ជកម្ម

-សភាការងារ និងសន្តិសុខសង្គម និង

-សភាអនិតិជន។ (ឯ.ឧ.ផូវ សំភី និងសរសេបន្ថែមមាត្រាអនិតិជន)

សភានីមួយៗចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងនាមសាលាដំបូងដែលសភានោះស្ថិតនៅ។

មាត្រា ១០..

សភានីមួយៗ ធ្វើការសម្រេចសេចក្តីលើរឿងក្តីស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនស្របច្បាប់ និងនីតិវិធីជាធរមាន។

មាត្រា ១១..

សមាសភាពរបស់សភានីមួយៗរួមមាន៖

-ប្រធានសភា

-ចៅក្រម

-ក្រឡាបញ្ជី។

ប្រធានសភានីមួយៗត្រូវចាត់តាំងដោយប្រធានសាលាដំបូង។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាដំបូង។

មាត្រា ១២..

សភានីមួយៗនៃសាលាដំបូងសម្រេចសេចក្តីដោយមានចៅក្រមមួយ(០១)រូប ឬបី (០៣)រូប អនុលោមតាមបទបញ្ញត្តិស្តីពីនិតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទបញ្ញត្តិ ស្តីពីនិតិវិធីផ្សេងទៀត។

ក្នុងករណីដែលចៅក្រមណាម្នាក់នៃសភាមួយមានធុរៈ ឬមានជំងឺលំដាប់នៃការផ្លាស់ប្តូរត្រូវធ្វើតាមដីកាសម្រេចប្រចាំឆ្នាំរបស់សាលាដំបូង។ ក្នុងករណីដែលសភាណាមួយមិនអាចបើកសវនាការបានដោយមានមូលហេតុមកពីខ្វះចៅក្រម ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមពីសភាផ្សេងមកបំពេញ។ ប្រសិនបើត្រូវស្នើសុំចៅក្រមម្នាក់ ឬច្រើននាក់នៃសាលាដំបូងផ្សេងសម្រាប់បំពេញសមាសភាពនៃសភានេះ ប្រធានសាលាដំបូងត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ១៣..

ប្រធានសាលាដំបូងចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរកានៃសាលាដំបូង។ ជារៀងរាល់ឆ្នាំក្នុងអំឡុងអឌ្ឍមាសទី១ នៃខែធ្នូ ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចសម្រាប់ឆ្នាំបន្ទាប់ខាងមុខ៖

-បែងចែកអនុប្រធាននៃសាលាដំបូង ឲ្យធ្វើជាប្រធានសភាទៅតាមឯកទេសរបស់ខ្លួន និងបែងចែកចៅក្រមសម្រាប់ធ្វើសមាជិកនៅក្នុងសភាទាំងនោះ។ ក្នុងករណីពុំទាន់មាន អនុប្រធាន ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមម្នាក់ដែលមានថ្នាក់ ឋានន្តរសក្តិខ្ពស់ ឬមានបទពិសោធន៍ការងារធ្វើជាប្រធានសភាបាន។

-កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងសភានីមួយៗ និងនៅក្នុងអង្គជំនុំជម្រះនៃសភាទាំងនេះ ក្នុងករណីចៅក្រមណាម្នាក់មានធុរៈ។

-ផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងសភានីមួយៗ។

-បែងចែកកម្មវិធីសវនាការ។

ដីកាទាំងនេះមិនអាចកែប្រែបានឡើយនៅក្នុងពេលកំពុងប្រតិបត្តិ លើកលែងតែមានករណីចាំបាច់។ ការកែប្រែនេះត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានសាលាដំបូង។

## មាត្រា ១៤..

ជារៀងរាល់ឆ្នាំ ប្រធានសាលាដំបូងចាត់តាំងចៅក្រម ដើម្បីទទួលបន្ទុកស៊ើបសួរដោយយោងតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ។

ក្នុងករណីចាំបាច់ ប្រធានសាលាដំបូងស៊ើបសួរអាចទទួលបំពេញមុខងារផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានសាលាដំបូង។

ក្នុងករណីណាក៏ដោយ ចៅក្រមស៊ើបសួរមិនអាចជំនុំជម្រះរឿងដែលទាក់ទងនឹងរឿងដែលខ្លួនបានស៊ើបសួរបានឡើយ។

មាត្រា ១៥..

សន្និបាតរបស់សាលាដំបូង ប្រព្រឹត្តនៅក្រោមអធិបតីភាពនៃប្រធានសាលាដំបូង ដើម្បីកំណត់អំពីកិច្ចការរដ្ឋបាលរបស់សាលាដំបូង។

## អនុផ្នែកទី២

## សមត្ថកិច្ច

មាត្រា ១៦..

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណា ដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការផ្សេងទៀត។

ក្នុងករណីចាំបាច់ ដើម្បីធានាសុវត្ថិភាព និងដំណើរការល្អនៃរដ្ឋបាលតុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀត តាមការស្នើសុំរបស់ប្រធានសាលាដំបូងដែលមានសមត្ថកិច្ច។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងសភាផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំប្រធានសភាដែលពាក់ព័ន្ធ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមសំណើរបស់ប្រធានសភាណាមួយ ដើម្បីសម្រេចអំពីសមត្ថកិច្ច។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

## ផ្នែកទី២

## អយ្យការអមសាលាដំបូង

មាត្រា ១៧..

-នៅអមសាលាដំបូង មានអយ្យការដែលមានសមាសភាព៖

-ព្រះរាជអាជ្ញា

-ព្រះរាជអាជ្ញារង

-នាយក្រឡាបបញ្ជី

-ក្រឡាបបញ្ជី និង

-មន្ត្រីរដ្ឋបាលផ្សេងទៀតដែលបម្រើការនៅអង្គការអយ្យការ។

មាត្រា ១៨..

ត្រូវបានបង្កើតលេខាធិការដ្ឋានរដ្ឋបាលសម្រាប់អយ្យការអមសាលាដំបូង ដែលទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មាត្រា ១៩..

មុខងារធ្វើបណ្ដឹងអាជ្ញារបស់អង្គការអយ្យការអមសាលាដំបូង ត្រូវបានប្រគល់ឲ្យព្រះរាជអាជ្ញាអមសាលាដំបូង។

ព្រះរាជអាជ្ញារងអមសាលាដំបូងចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាអមសាលាដំបូង។

មាត្រា ២០..

ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាបែងចែកព្រះរាជអាជ្ញារងអមសាលាដំបូង នៅក្នុងក្រុមការងារផ្សេងៗនៃអង្គការអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។ ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬចាត់ឲ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមតែខ្លួនយល់ឃើញថាជាការគួរ។

## ផ្នែកទី៣ សភានៃសាលាដំបូង

## អនុផ្នែកទី ១

## សភារដ្ឋបាល

មាត្រា ២១..

សភារដ្ឋបាលមានសមាសភាពជាចៅក្រមដែលត្រូវស្ថិតនៅក្រោមលក្ខន្តិកៈនៃអង្គចៅក្រម។ ប្រធានសភារដ្ឋបាល គឺជាចៅក្រមដែលត្រូវបានចាត់តាំងដោយប្រធានសាលាដំបូង។

មាត្រា ២២..

សាលក្រមរបស់សភារដ្ឋបាលត្រូវសម្រេចដោយអង្គជំនុំជម្រះ ដែលមានសមាសភាពជាចៅក្រមបីរូប លើកលែងតែមានបទបញ្ញត្តិចែងផ្សេងពីនេះ។

មាត្រា ២៣..

សភារដ្ឋបាលនៃសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីរដ្ឋបាល នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រឿងក្ដីរដ្ឋបាល គឺជាទំនាស់រវាងរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ជាមួយស្ថាប័នសាធារណៈ ឬទំនាស់រវាងស្ថាប័នសាធារណៈ ជាមួយស្ថាប័នសាធារណៈដែលទាក់ទិនសេចក្ដីសម្រេចដែលធ្វើឡើងដោយអាជ្ញាធររដ្ឋបាល នៅក្នុងការអនុវត្តបុព្វសិទ្ធិនៃអំណាចសាធារណៈរបស់ខ្លួន។

សភារដ្ឋបាលអាចចេញសាលក្រមសម្រេចទុកជាមោឃៈមួយផ្នែក ឬទាំងស្រុង នៃសេចក្ដីសម្រេចនៃអាជ្ញាធររដ្ឋបាល។

សភារដ្ឋបាលអាចចេញសាលក្រមសម្រេចទុកជាមោឃៈ ចំពោះសេចក្តីសម្រេចដែលចេញដោយអាជ្ញាធររដ្ឋបាលបាន ក្នុងករណីដូចជា អសមត្ថកិច្ច វិការៈផ្នែកទម្រង់ ការរំលោភអំណាច និងការបំពានច្បាប់។

សភារដ្ឋបាល គឺអាចសម្រេចលើបណ្តឹងទាមទារសំណង ការខូចខាតដែលទាក់ទងជាមួយនឹងរឿងក្តីរដ្ឋបាលខាងលើផងដែរ។

មាត្រា ២៤..

សេចក្តីសម្រេចរបស់សភារដ្ឋបាលនៃសាលាដំបូង បើកផ្លូវប្តឹងឧទ្ធរណ៍។

## អនុផ្នែកទី២

## សភាពាណិជ្ជកម្ម

មាត្រា២៥..

សភាពាណិជ្ជកម្មមានសមាសភាពជាចៅក្រម ទីប្រឹក្សាពាណិជ្ជកម្ម និងក្រឡាបញ្ជី។ បែបបទលក្ខខណ្ឌនៃការបោះឆ្នោតជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្មត្រូវកំណត់ដោយអនុក្រឹត្យ។

ទីប្រឹក្សាពាណិជ្ជកម្មពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាជម្រះក្តីពាណិជ្ជកម្មនៃសាលាដំបូងឡើយ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូងតាមការអញ្ជើញរបស់ប្រធានសភាពាណិជ្ជកម្ម។

មាត្រា២៦..

សភាពាណិជ្ជកម្មត្រូវជំនុំជម្រះដោយចៅក្រមមួយរូប អមដោយទីប្រឹក្សាពាណិជុជកម្មពីររូប។ សាលក្រមរបស់សភាពាណិជ្ជកម្មត្រូវសម្រេចដោយចៅក្រមមួយរូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្មពីររូប។

មាត្រា២៧..

សភាពាណិជ្ជកម្មនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីពាណិជ្ជកម្មដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតំលៃក្រោម ឬស្មើ ៥០លានរៀល សភាពាណិជ្ជកម្មធ្វើការសម្រេចសេចក្តី ដោយចៅក្រម ១រូប ដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្មឡើយ។

រឿងក្តីពាណិជ្ជកម្មមានជាអាទ៍៖

-វិវាទរវាងពាណិជ្ជករ និងពាណិជ្ជករ ទាក់ទងនិងពាណិជ្ជកិច្ច (នឹងពិនិត្យច្បាប់កិច្ចសន្យាពាណិជ្ជកម្ម ដើម្បីបន្ថែមន័យទៀត)។

-វិវាទរវាងម្ចាស់ភាគហ៊ុន និងម្ចាស់ភាគហ៊ុន ឬរវាងម្ចាស់ភាគហ៊ុន និងក្រុមហ៊ុន។ សភាពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងជំទាស់ ការទទួលស្គាល់ និងការឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យពាណិជ្ជកម្ម។

សភាពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះអំពីការស្តារ និងការជម្រះបញ្ជីតាមផ្លូវតុលាការរបស់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្ម។

មាត្រា ២៨..

នីតិវិធីនៅមុខសភាពាណិជ្ជកម្ម និងថិរវេលានៃបណ្តឹងឧទ្ធរណ៍ ត្រូវអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីតដ្ឋប្បវេណី លើកលែងតែមានច្បាប់ចែងផ្សេងពីនេះ។

## អនុផ្នែកទី៣

## សភាការងារ និងសន្តិសុខសង្គម

មាត្រា ២៩..

សភាការងារ និងសន្តិសុខសង្គមមានសមាសភាពជាចៅក្រម ទីប្រឹក្សាការងារ និងសន្តិសុខសង្គម និងក្រឡាបបញ្ជី។ បែបបទ លក្ខខណ្ឌនៃការបោះឆ្នោតជ្រើសតាំង និងការបំពេញភារៈកិច្ចរបស់ទីប្រឹក្សាការងារ និងសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

ទីប្រឹក្សាការងារ និងសន្តិសុខសង្គម ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍នៅក្នុងសភាជម្រះក្តីការងារ និងសន្តិសុខសង្គមនៃសាលាដំបូងឡើយ។ ទីប្រឹក្សាការងារ និងសន្តិសុខសង្គមត្រូវចូលបំពេញមុខងាររបស់ខ្លួននៅសាលាដំបូង តាមការអញ្ជើញរបស់ប្រធានសភាការងារ និងសន្តិសុខសង្គម។

មាត្រា ៣០..

សភាការងារ និងសន្តសុខសង្គមត្រូវជំនុំជម្រះដោយចៅក្រមមួយរូប អមដោយទីប្រឹក្សាការងារ និងសន្តិសុខសង្គមពីរូប។

សាលក្រមរបស់ការងារ និងសន្តិសុខសង្គម ត្រូវការសម្រេចដោយចៅក្រម ០១ រូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ និងសន្តិសុខសង្គម ពីររូប ដែលមួយរូបជាកម្មករនិយោជិត និងមួយរូបទៀតជានិយោជក។

មាត្រា ៣១..

សភាការងារ និងសន្តិសុខសង្គមនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីពាក់ព័ន្ធនឹងនីតិការងារ និងបទបញ្ញត្តិស្តីពីការងារ និងសន្តិសុខសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

មាត្រា ៣២..

សភាការងារ និងសន្តិសុខសង្គមមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដូចតទៅះ

-វិវាទបុគ្គលពាក់ព័ន្ធការងារ ដែលកើតមានឡើងរវាងនិយោជក និងកម្មករនិយោជិត ឬកូនជាងម្នាក់ ឬច្រើននាក់តាមរឿងរៀងៗខ្លួន ដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តកិច្ចសន្យាការងារហ្វឹកហ្វឺនកូនជាង អនុសញ្ញារួម ឬបទបញ្ញត្តិច្បាប់ពាក់ព័ន្ធជាធរមាន។

-វិវាទរួមពាក់ព័ន្ធការងារដែលកើតមានឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់(ជាមួយ) និងកម្មករនិយោជិតរបស់ខ្លួនមួយចំនួន ទាក់ទងនឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិរបស់អង្គការវិជ្ជាជីវៈ ក្នុងសហគ្រាសគ្រឹះស្ថានដែលវិវាទនេះអាចបណ្តាឲ្យ សហគ្រាស គ្រឹះស្ថានប្រព្រឹត្តទៅពុំបានល្អ ឬធ្វើឲ្យប៉ះពាល់ដល់សន្តិភាពសង្គម។

-សម្រេចអំពីនីត្យានុកូលភាពនៃកូដកម្ម។

-ដោះស្រាយវិវាទដែលកើតចេញពីការអនុវត្តបទបញ្ញត្តិ នៃច្បាប់ស្តីពីការងារទាក់ទងនឹងសេរីភាពសហជីព។ (ពិគ្រោះយោបល់ជាមួយឯ.ឧ.តុលា ចំពោះពាក្យសិទ្ធិសហជីព)

-ជំនុំជម្រះវិវាទស្តីអំពីសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត និងភាពត្រឹមត្រូវនៃការបោះឆ្នោតជ្រើសតាំងប្រតិភូសហជីព។ វិវាទនេះត្រូវជំនុំជម្រះបន្ទាន់ និង បិទផ្លូវតវ៉ា។

-ជំនុំជម្រះវិវាទទាក់ទងនឹងរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ។

-សភាការងារ និងសន្តិសុខសង្គមក៏អាចដោះស្រាយបណ្តឹងជំទាស់ និងមជ្ឈត្តវិនិច្ឆ័យផ្នែកការងារផងដែរ។

## មាត្រា ៣៣..

សភាការងារ និងសន្តិសុខសង្គមដែលមានសមត្ថកិច្ច គឺសភាការងារ និងសន្តិសុខសង្គមនៃសាលាដំបូងនាទីកន្លែងធ្វើការងារ។

ទោះបីមានមានការកំណត់សមត្ថកិច្ចដូចកថាខណ្ឌខាងលើក៏ដោយ ក៏កម្មករនិយោជិតអាចប្តឹងទៅសាលាដំបូងតាមការកំណត់ដូចខាងក្រោមះ

-នាទីលំនៅឋានរបស់ខ្លួនឬ

-នាទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុនឬ

-នាទីលំនៅឋានរបស់អ្នកតំណាង ឬអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុន ប្រសិនបើ គ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុនទេ។

## មាត្រា ៣៤..

សេចក្តីសម្រេចរបស់សភាការងារ និងសន្តិសុខសង្គមបើកផ្លូវឧទ្ធរណ៍ លើកលែងតែមានបញ្ញត្តិផ្សេងពីនេះ។

# ជំពូកទី៣

# តុលាការយោធា

មាត្រា ៣៥..

តុលាការយោធាមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

មាត្រា ៣៦..

តុលាការយោធាមានសមត្ថកិច្ចជំនុំជម្រះបទល្មើសយោធា។ សេចក្តីសម្រេចរបស់តុលាការយោធាបើកសិទ្ធិប្តឹងឧទ្ធរណ៍ និងប្តឹងសារទុក្ខ។

មាត្រា ៣៧..

ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការយោធា ត្រូវកំណត់ដោយច្បាប់ដោយឡែក។

# ជំពូកទី៤

# សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

## ផ្នែកទី១ សាលាឧទ្ធរណ៍

### អនុផ្នែកទី១ ការរៀបចំនិងការប្រព្រឹត្តទៅ

មាត្រា ៣៨..

សាលាឧទ្ធរណ៍គឺជាសាលាជម្រះក្តីជាន់ខ្ពស់ដែលមានទីតាំង និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការកំណត់របស់ច្បាប់។

សមាសភាពសាលាឧទ្ធរណ៍រួមមាន៖

-ប្រធាន

-អនុប្រធាន

-ចៅក្រម

-នាយក្រឡាបបញ្ជី

-ក្រឡាបបញ្ជី និង

-មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបំរើការនៅសាលាឧទ្ធរណ៍។

មាត្រា ៣៩..

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានរដ្ឋបាលសម្រាប់សាលាឧទ្ធរណ៍ ដែលទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៤០..

សាលាឧទ្ធរណ៍មានសភាដូចខាងក្រោម៖

-សភារដ្ឋប្បវេណី

-សភាព្រហ្មទណ្ឌ

-សភារដ្ឋបាល

-សភាពាណិជ្ជកម្ម និង

-សភាការងារ និងសន្តិសុខសង្គម។

សភានីមួយៗចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងនីតិវិធីជាធរមានក្នុងនាមសាលាឧទ្ធរណ៍ដែលសភានោះស្ថិតនៅ។

មាត្រា ៤១..

សភារដ្ឋប្បវេណីមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រម និងជំនុំជម្រះបណ្តឹងជំទាស់ ចំពោះដីកាសម្រេចរបស់សាលាដំបូង ក្នុងរឿងក្តីរដ្ឋប្បវេណីដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។

មាត្រា ៤២..

សភាព្រហ្មទណ្ឌមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ក្នុងរឿងក្តីព្រហ្មទណ្ឌដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ។

កាលបើសភាព្រហ្មទណ្ឌសម្រេចអំពីរឿងឧក្រិដ្ឋ សាលដីកាត្រូវសម្រេចដោយចៅក្រម ០៥ រូប រាប់ទាំងប្រធានសភាផង។

មាត្រា ៤៣..

សភាស៊ើបសួរមានតួនាទីជំនុំជម្រះតែលើរឿងទាំងឡាយណា ដែលមានបទបញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងទៀតប្រគល់ឲ្យ។

មាត្រា ៤៤..

សភារដ្ឋបាលមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ក្នុងរឿងក្តីរដ្ឋបាល ដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល។

សភារដ្ឋបាលនៃសាលាឧទ្ធរណ៍ មានសមាសភាពជាចៅក្រម និងទីប្រឹក្សារដ្ឋបាល។

ទីប្រឹក្សារដ្ឋបាលមានចំនួនយ៉ាងតិច ០៥ រូប។ បែបបទ និងលក្ខខណ្ឌនៃការជ្រើសរើសទីប្រឹក្សារដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។ (យកខ្លឹមសារមាត្រា៤៨ចាស់ដែលបានលុបចោល)

សាលក្រមរបស់សភារដ្ឋបាល ត្រូវសម្រេចដោយចៅក្រមបីរូប បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សារដ្ឋបាលចំនួនពីររូប។

ទីប្រឹក្សារដ្ឋបាលចូលរួមក្នុងសវនាការ និងអាចចោទសួរភាគីឬសាក្សីតាមរយៈប្រធានសវនាការ ប៉ុន្តែពុំមានសិទ្ធិចូលរួមពិភាក្សាសម្រេចសេចក្តីឡើយ។ (យកខ្លឹមសារមាត្រា៥២ចាស់ដែលបានលុបចោល)

## មាត្រា ៤៥..

សភាពាណិជ្ជកម្មមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ រឿងក្តីពាណិជ្ជកម្មដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម។

## មាត្រា ៤៦..

សភាការងារ និងសន្តិសុខសង្គមមានតួនាទីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ រឿងក្តីការងារ និងសន្តិសុខសង្គម ដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីការងារ និងសន្តិសុខសង្គម។

## មាត្រា ៤៧..

សមាសភាពរបស់សភានីមួយៗរួមមានៈ

-ប្រធានសភា

-ចៅក្រម

-ក្រឡាបញ្ជី

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍។

សភានីមួយៗត្រូវមានចៅក្រមយ៉ាងតិច ៣រូប រួមទាំងប្រធានសភាផង។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍។

## មាត្រា ៤៨..

សភានីមួយៗត្រូវជំនុំជម្រះដោយចៅក្រម ០៣រូប ដែលមួយរូបជាប្រធាន។

សមាសភាពនេះ ចាំបាច់ត្រូវបំពេញដោយតំណាងអង្គការអយ្យការអមសាលាឧទ្ធរណ៍ចំពោះគ្រប់រឿងក្តីព្រហ្មទណ្ឌទាំងអស់។

រឿងក្តីណាដែលតុលាការកំពូលបានបង្វិលមកវិញនោះ សាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រម ០៣រូប ឬប្រសិនបើរឿងឧក្រិដ្ឋវិញនោះ ត្រូវជំនុំជម្រះដោយចៅក្រម ០៥រូប ហើយសុទ្ធតែជាចៅក្រមដែលមិនចូលរួមជំនុំជម្រះលើកមុន។

## មាត្រា ៤៩..(ឯ.ឧ.ផូវ សំភី ស្រាវជ្រាវ)

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះ បានទទួល ឬអាចទទួលបាននូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខផ្សេងគ្នា។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍ ឬតាមការស្នើរបស់ប្រធានសភាណាមួយទៅប្រធានសាលាឧទ្ធរណ៍។

សេចក្តីសម្រេចរបស់សភារួមក្រុម អំពីការបែងចែកសមត្ថកិច្ចរវាងសភាផ្សេងៗនៃសាលាឧទ្ធរណ៍ និងវិវាទច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម។

កាលបើសភារួមក្រុមត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពជា ចៅក្រមយ៉ាងតិច ០៧ រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ចៅក្រមទាំងនេះតំណាងឲ្យសភាយ៉ាងតិចចំនួនពីរនៃសាលាឧទ្ធរណ៍។ សភាស៊ើបសួរពុំអាចចូលរួមបង្កើតសភារួមក្រុមបានឡើយ។

សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍។

ប្រធានសាលាឧទ្ធរណ៍ចេញដីកាសម្រេចដោយអនុលោមតាម សេចក្តីសម្រេចរបស់សភារួមក្រុម។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

## មាត្រា ៥០..

សន្និបាតនៃសាលាឧទ្ធរណ៍ ត្រូវប្រព្រឹត្តឡើងក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ ដើម្បីកំណត់អំពីកិច្ចការរដ្ឋបាលនៃសាលាឧទ្ធរណ៍។

## មាត្រា ៥១..

ជារៀងរាល់ឆ្នាំ ប្រធានសាលាឧទ្ធរណ៍ត្រូវសម្រេចទុកជាមុន តាមដីកាសម្រេចនូវលំដាប់នៃការជំនួសចៅក្រម ចំពោះករណីដែលចៅក្រមនៃសភាណាមួយអវត្តមាន ឬមានធុរៈ។ (យកពីមាត្រា ៤៨)

ប្រធានសាលាឧទ្ធរណ៍ចាត់វិធានការគ្រប់គ្រងជាចាំបាច់ ក្នុងការប្រព្រឹត្តទៅនៃសាលាឧទ្ធរណ៍ ជាពិសេសជារៀងរាល់ឆ្នាំ នៅក្នុងអឌ្ឍមាសទីមួយនៃខែធ្នូប្រធានសាលាឧទ្ធរណ៍ត្រូវចេញដីកាសម្រេច សម្រាប់ឆ្នាំបន្ទាប់ខាងមុខ៖

-ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ម្នាក់ ឬ បើគ្មានអនុប្រធាននេះទេ អាចចាត់តាំងចៅក្រមណាម្នាក់ធ្វើជាប្រធានជំនួសខ្លួនបានក្នុងករណីចាំបាច់។

-ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗ ទៅតាមជំនាញឯកទេស។ ក្នុងករណីខ្វះ ឬពុំមានអនុប្រធានសាលាឧទ្ធរណ៍ ប្រធានសាលាឧទ្ធរណ៍អាចចាត់តាំងចៅក្រមម្នាក់ ដែលមានថ្នាក់ឋានន្តរសក្តិខ្ពស់ ឬមានបទពិសោធន៍ការងារធ្វើជាប្រធានសភាបាន។

-បែងចែកអនុប្រធានសាលាឧទ្ធរណ៍ និងចៅក្រម និងផ្លាស់ប្តូរក្រឡាបញ្ជីទៅតាមសភានីមួយៗ

-កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងសភា និងក្នុងអង្គជំនុំជម្រះ ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ។

-ចាត់តាំងចៅក្រមដែលត្រូវចូលរួមជាសមាសភាព នៅក្នុងពេលសវនាការជំនុំជម្រះរឿងក្តីដែលតុលាការកំពូលបានបង្វិលមកវិញ។

-បែងចែកកម្មវិធីសវនាការ។

មាត្រា ៥២..

ចៅក្រមអាសនៈនៃសាលាឧទ្ធរណ៍មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ដែលទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងដំណើរការរបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអាសនៈនៃសាលាឧទ្ធរណ៍។

-អគ្គលេខាធិការរដ្ឋបាលរបស់ចៅក្រមអាសនៈនៃសាលាឧទ្ធរណ៍ ដោះស្រាយបញ្ហាដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអាសនៈនៃសាលាឧទ្ធរណ៍

-អគ្គលេខាធិការដ្ឋាននៃចៅក្រមអាសនៈកំណត់ជាអាទិ៍នៃប្រតិទិនសវនាការ ដោយផ្អែកលើភាពចាំបាច់នៃការគ្រប់គ្រងដ៏ល្អផ្នែកតុលាការ។

-ដំណើរការរបស់អគ្គលេខាធិការដ្ឋាននៃចៅក្រមអាសនៈ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ចៅក្រមមួយរូបដែលត្រូវបានចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍។

បទបញ្ជាផ្ទៃក្នុងចៅក្រមអាសនៈនៃសាលាឧទ្ធរណ៍ ត្រូវតាក់តែងឡើងក្រោមការដឹកនាំរបស់ប្រធានសាលាឧទ្ធរណ៍ និងបង្ខំឲ្យចៅក្រមទាំងអស់អនុវត្តតាម។

## អនុផ្នែកទី២

## សមត្ថកិច្ច

មាត្រា ៥៣..

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចឲ្យតុលាការផ្សេងទៀត។

ក្នុងករណីដែលមានច្បាប់បង្កើតសាលាឧទ្ធរណ៍តាមតំបន់ទៀតនោះ សាលាឧទ្ធរណ៍ចាស់ដែលបានទទួលបណ្តឹងរួចមកហើយ ហើយកំពុងចាត់ការនៅតែមានសមត្ថកិច្ចដដែលដើម្បីសម្រេចសេចក្តី។ ប៉ុន្តែសំណុំរឿងទាំងឡាយណាដែលសាលាឧទ្ធរណ៍បានទទួលរួចហើយតែពុំទាន់បានចាត់ការ ត្រូវផ្ទេរសំណុំរឿងដោយស្វ័យប្រវត្តិជូនសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចវិញ។

មាត្រា ៥៤..

សាលាឧទ្ធរណ៍សម្រេចសេចក្តីទាំងអង្គហេតុ និងច្បាប់។

សាលាឧទ្ធរណ៍មានសមត្ថកិច្ច សម្រេចសេចក្តីលើករណីដូចតទៅៈ

បណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចរបស់សាលាដំបូង ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

បណ្តឹងតវ៉ាពីសមត្ថកិច្ចរបស់សាលាដំបូង និងអំពីវិវាទសមត្ថកិច្ចរវាងសាលាដំបូងទាំងឡាយលើកលែងតែក្នុងករណីមានច្បាប់ផ្សេងពីនេះ។

-បណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចរបស់តុលាការយោធា ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-រឿងក្តីដែលតុលាការកំពូលបានបង្វិលមកវិញ។

-ប្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងលក្ខន្តិកៈរបស់មេធាវី។

-បណ្តឹងជំទាស់ និងដីកាសម្រេចរបស់សាលាដំបូង ដែលសម្រេចឲ្យចេញដីកាឪកាសទានអនុវត្តសេចក្តីសម្រេចមជ្ឈត្តករជាតិ។

-ពាក្យសុំចេញដីកាឪកាសទានអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេស។

## ផ្នែកទី២

## មហាអយ្យការអមសាលាឧទ្ធរណ៍

មាត្រា ៥៥..

នៅអមសាលាឧទ្ធរណ៍ មានមហាអយ្យការដែលមានសមាសភាពៈ

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញារង

-ព្រះរាជអាជ្ញា

-នាយក្រឡាបបញ្ជី

-ក្រឡាបបញ្ជី និង

-មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបម្រើការនៅមហាអយ្យការ។

មាត្រា ៥៦..

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានរដ្ឋបាល សម្រាប់មហាអយ្យការអមសាលាឧទ្ធរណ៍ដែលទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៥៧..

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអជ្ញាអមសាលាឧទ្ធរណ៍។

មាត្រា ៥៨..

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បែងចែកអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅក្នុងក្រុមការងារផ្សេងៗ នៃមហាអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចលើថៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិបញ្ញាឲ្យចោទប្រកាន់ ឬចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។ ប៉ុន្តែ នៅក្នុងពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន។

## ជំពូកទី ៥

## តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

## ផ្នែកទី ១

## តុលាការកំពូល

### អនុផ្នែកទី ១

### ការរៀបចំ និងការប្រព្រឹត្តទៅ

មាត្រា ៥៩..

តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ។

មាត្រា ៦០..

តុលាការកំពូលមានសមាសភាព៖

-ប្រធាន

-អនុប្រធាន

-ចៅក្រម

-នាយកក្រឡាបញ្ជី

-ក្រឡាបញ្ជី និង

-មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបម្រើការនៅតុលាការកំពូល។

មាត្រា ៦១..

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានរដ្ឋបាលសម្រាប់តុលាការកំពូល ដែលទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៦២..

តុលាការកំពូលមានសភាដូចតទៅ៖

-សភារដ្ឋប្បវេណី

-សភាព្រហ្មទណ្ឌ

-សភារដ្ឋបាល

-សភាពាណិជ្ជកម្ម និង

-សភាការងារ និងសន្តិសុខសង្គម។

សភានីមួយៗចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងនាមតុលាការកំពូល។

មាត្រា ៦៣..

សភារដ្ឋប្បវេណី មានតួនាទីជំនុំជម្រះលើបណ្តឹងសារទុក្ខនឹងសាលដីកា បណ្តឹងជំទាស់ នឹងដីកាសម្រេចរបស់សាលាឧទ្ធរណ៍ ព្រមទាំងសាលក្រមរបស់សាលាដំបូង ក្នុងរឿងក្តីរដ្ឋប្បវេណី រឿងក្តីអនីតិជន និងគ្រួសារដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។

មាត្រា ៦៤ ..

សភាព្រហ្មទណ្ឌមានតួនាទីជំនុំជម្រះលើបណ្ដឹងសារទុក្ខក្នុងរឿងក្ដីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទបញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ។

មាត្រា ៦៥..

សភារដ្ឋបាលមានតួនាទីជំនុំជម្រះលើបណ្ដឹងសារទុក្ខក្នុងរឿងក្ដីរដ្ឋបាល ដោយអនុវត្តតាមបទបញ្ញត្តិស្ដីពីនីតិវិធីរដ្ឋបាល។

មាត្រា ៦៦..

សភាពាណិជ្ជកម្ម មានតួនាទីជំនុំជម្រះលើបណ្ដឹងសារទុក្ខ ក្នុងរឿងក្ដីពាណិជ្ជកម្មដោយអនុវត្តតាមបទបញ្ញត្តិស្ដីពីនីតិវិធីពាណិជ្ជកម្ម។

មាត្រា ៦៧..

សភាការងារ និងសន្តិសុខសង្គម មានតួនាទីជំនុំជម្រះលើបណ្ដឹងសារទុក្ខក្នុងរឿងក្ដីការងារ និងសន្តិសុខសង្គមដោយអនុវត្តតាមបទបញ្ញត្តិស្ដីពីនីតិវិធីការងារ និងសន្តិសុខសង្គម។

មាត្រា ៦៨..

សមាសភាពរបស់សភានីមួយៗ រួមមានៈ

-ប្រធានសភា

-ចៅក្រម

-ក្រឡាបញ្ជី

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល។

សភានីមួយៗត្រូវមានចៅក្រមយ៉ាងតិច ៥រូប រួមទាំងប្រធានសភាផង។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល។

មាត្រា ៦៩..

សមាសភាពនៃអង្គជំនុំជម្រះរបស់សភានីមួយៗត្រូវមានចៅក្រម ៥រូប ដែលមានប្រធានមួយរូប និងក្រឡាបញ្ជីមួយរូប ឬច្រើនរូបតាមការចាំបាច់។ សមាសភាពនេះចាំបាច់ត្រូវមានតំណាងមហាអយ្យការអមតុលាការកំពូល ចូលរួមចំពោះរឿងក្ដីព្រហ្មទណ្ឌ ជារៀងរាល់ឆ្នាំប្រធានតុលាការកំពូលសម្រេចទុកជាមុន តាមដីកាសម្រេចនៅលំដាប់នៃការជំនួសចៅក្រម ចំពោះករណីដែលចៅក្រមនៃសភាណាមួយអវត្តមាន ឬមានធុរៈ។

មាត្រា ៧០..

ប្រធានតុលាការកំពូលចាត់វិធានការគ្រប់គ្រងជាចាំបាច់ ក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូលជារៀងរាល់ឆ្នាំនៅក្នុងអឌ្ឍមាសទី១ នៃខែធ្នូ ប្រធានតុលាការកំពូលធ្វើដីកាសម្រេចសម្រាប់ឆ្នាំបន្ទាប់ ដើម្បីៈ

-ចាត់តាំងអនុប្រធានតុលាការកំពូលមួយរូប ឬបើគ្មានអនុប្រធានទេ ចាត់តាំងចៅក្រមណាម្នាក់ ដើម្បីជំនួសខ្លួនបានក្នុងករណីចាំបាច់។

-ចាត់តាំងអនុប្រធានតុលាការកំពូលឲ្យទទួលបន្ទុក ធ្វើជាប្រធានសភានីមួយៗទៅតាមជំនាញ។ ក្នុងករណីខ្វះអនុប្រធាន ឬពុំមានអនុប្រធានតុលាការកំពូល ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមម្នាក់ដែលមានថ្នាក់ ឋានន្តរសក្តិខ្ពស់ ឬមានបទពិសោធន៍ការងារធ្វើជាប្រធានសភាបាន។

-ចាត់តាំងចៅក្រមជំនួសក្នុងករណីដែលចៅក្រមនៃសភាណាមួយអវត្តមាន ឬ មានធុរៈ។

-បែងចែកភារកិច្ចដល់ចៅក្រមទៅតាមសភានីមួយៗតាមជំនាញ។

-បែងចែកអនុប្រធានតុលាការកំពូល និងចៅក្រម និងផ្លាស់ប្តូរក្រឡាបញ្ជីតាមសភានីមួយៗ។

-ចាត់តាំងចៅក្រមធ្វើជាសមាសភាពនៃអង្គជំនុំជម្រះ សភារួមក្រុម។

ដីកាសម្រេចទាំងនេះមិនអាចកែប្រែបានឡើយ លើកលែងតែករណីដែលចៅក្រមណាម្នាក់មានការងារច្រើនពេក ឬត្រូវឈប់ពីតំណែង ឬផ្លាស់ប្តូរទៅកាន់តុលាការផ្សេង ឬបន្តមានធុរៈដោយមូលហេតុឈប់សម្រាករយៈពេលវែងជាដើម។

## មាត្រា ៧១..

សន្និបាតនៃតុលាការកំពូល ត្រូវប្រព្រឹត្តឡើងក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ដើម្បីកំណត់អំពីកិច្ចការរដ្ឋបាលនៃតុលាការកំពូល។

## មាត្រា ៧២..

ចៅក្រមអាសនៈនៃតុលាការកំពូល ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការដែលទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងដំណើរការរបស់អគ្គលេខាធិការដ្ឋាននេះត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់តុលាការកំពូល។

អគ្គលេខាធិការដ្ឋាននេះ ៖

-ដោះស្រាយបញ្ហាដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអាសនៈ នៃតុលាការកំពូល។

-កំណត់ជាអាទិ៍នូវប្រតិទិននៃសវនាការ ដោយផ្អែកលើភាពចាំបាច់នៃការគ្រប់គ្រងដ៏ល្អនៃតុលាការ។

ដំណើរការនៃអគ្គលេខាធិការដ្ឋាននៃចៅក្រមអាសនៈ ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ចៅក្រមមួយរូប ដែលចាត់តាំងដោយប្រធានតុលាការកំពូល។

បទបញ្ជាផ្ទៃក្នុងរបស់ចៅក្រមអាសនៈនៃតុលាការកំពូលត្រូវតាក់តែងឡើង ក្រោមការដឹកនាំរបស់ប្រធានតុលាការកំពូល និងបង្ខំឲ្យចៅក្រមទាំងអស់អនុវត្ត។

## អនុផ្នែកទី ២

## សមត្ថកិច្ច

### មាត្រា ៧៣..

តុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើៈ

-បណ្ដឹងសារទុក្ខទាំងឡាយ ដែលសុំបដិសេធសាលក្រម ឬសាលដីការបស់តុលាការដោយផ្អែកលើបទបញ្ញត្តិស្ដីពីនីតិវិធី។

-បណ្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍។

-បណ្ដឹងសើរើចំពោះសាលក្រម ឬសាលដីកាស្ថាពរ លើកលែងតែបទបញ្ញត្តិផ្សេងថែងផ្ទុយពីនេះ។

-ភាពមិនច្បាស់លាស់នៃដែនសមត្ថកិច្ចរបស់តុលាការថ្នាក់ក្រោម ក្នុងរឿងរដ្ឋប្បវេណីដោយអនុលោមតាមនីតិវិធីរដ្ឋប្បវេណី និងបញ្ហាផ្សេងទៀតដែលច្បាប់បានកំណត់ (ពិនិត្យក្នុងនិតិវិធីរដ្ឋប្បវេណីឡើងវិញ)

តុលាការកំពូលអាចមានអំណាចពិសេស ដែលកំណត់ដោយច្បាប់ផ្សេងទៀត។

តុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើអង្គច្បាប់ ពុំមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុឡើយ លើកលែងតែមានបទបញ្ញត្តិច្បាប់ថែងផ្ទុយពីនេះ។

### មាត្រា ៧៤..(ឯ.ឧ. ផូវ សំភី សិក្សាបន្ថែមនៅវាក្យខណ្ឌទី ១) (យកពីមាត្រា១៥ ដែលបានលុបចោល)

សភាពេញអង្គអាចបង្កើតឲ្យមានដំណើរការបាន កាលបើរឿងក្ដីមួយចោទឡើងនូវបញ្ហាគោលការណ៍ដែលមានជាអាទិ៍ដូចជា ក្នុងករណីមានដំណោះស្រាយខ្វែងគ្នារវាង ចៅក្រមអង្គសេចក្ដី និងចៅក្រមអង្គសេចក្ដី ឬរវាងចៅក្រមអង្គសេចក្ដី និងតុលាការកំពូល។

នៅក្នុងរឿងព្រហ្មទណ្ឌ ការបញ្ជូនសំណុំរឿងទៅសភាពេញអង្គ ត្រូវធ្វើឡើងដាច់ខាតចំពោះបណ្ដឹងសារទុក្ខលើកទីពីរ លើសាលដីកាសាលាឧទ្ធរណ៍ដែលត្រូវបដិសេធដោយហេតុផលដដែលអនុលោមតាមបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញ

របស់ប្រធានតុលាការកំពូល ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយទៅប្រធានតុលាការកំពូល។

សភាពេញអង្គនៃតុលាការកំពូល គឺជាអង្គជំនុំជម្រះ ដែលចេញសេចក្តីសម្រេចតុលាការ។

កាលបើសភាពេញអង្គត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ៩រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាទាំងអស់ នៃតុលាការកំពូល។

សភាពេញអង្គស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។

មាត្រា ៧៥..(យកពីមាត្រា ១៦ចាស់ដែលបានលុបចោល)

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួល ឬអាចទទួលបាននូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នា។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយទៅប្រធានតុលាការកំពូល។

សេចក្តីសម្រេចរបស់សភារួមក្រុមអំពីការបែងចែកសមត្ថកិច្ចរវាងសភាផ្សេងៗ នៃតុលាការកំពូល និងវិវាទច្បាប់មានអំណាចបង្ខំឲ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម។

កាលបើសភារួមក្រុមត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពជា ចៅក្រមយ៉ាងតិច ៩ រូប ដែលបែចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ។ ចៅក្រមទាំងនេះអាចតំណាងឲ្យសភាយ៉ាងតិចចំនួនពីរ នៃតុលាការកំពូលក៏បាន។

សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។

ប្រធានតុលាការកំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

## ផ្នែកទី ២

## មហាអយ្យការ

មាត្រា ៧៦.. (យកពីមាត្រា ៦១)

នៅអមតុលាការកំពូល មានមហាអយ្យការដែលមានសមាសភាព ៖

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-អគ្គព្រះរាជអាជ្ញារង

-ព្រះរាជអាជ្ញា

-នាយកក្រឡាបញ្ជី

-ក្រឡាបញ្ជី និង

-មន្ត្រីរដ្ឋបាលផ្សេងទៀត ដែលបម្រើការនៅមហាអយ្យការ។

មាត្រា ៧៧..

ត្រូវបង្កើតអគ្គលេខាធិការដ្ឋានរដ្ឋបាលសម្រាប់មហាអយ្យការអមតុលាការកំពូល ដែលទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៧៨..

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ទៅឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមក្នុងការសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសារទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ។(ដកស្រង់ពីមាត្រា ៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

មាត្រា ៧៩..

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលបែងចែក អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល នៅក្នុងក្រុមការងារផ្សេងៗនៃអង្គការអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។

សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនៅមុនពេលសវនាការ។ ប្រសិន បើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយម្ចាស់នៃសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯង តែម្តងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ។

ប៉ុន្តែនៅក្នុងពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនឃើញថា សមស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។

## ជំពូកទី ៦
## វិសមត្ថភាព

មាត្រា ៨០..

ចៅក្រមមិនអាចចូលរួមជំនុំជម្រះនូវរឿងក្តីតែមួយជាមួយសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ ៤ (បួន) រាប់ទាំងថ្នាក់ទី(បួន) នេះផងទោះនៅក្នុងឋានៈ ជាចៅក្រមក្តី ជាចៅក្រមអយ្យការក្តី ឬក៏ម្នាក់ជំនុំជម្រះនៅសាលាឧទ្ធរណ៍ ឬតាមតុលាការកំពូលនូវរឿងដែលម្នាក់ទៀតបានជំនុំជម្រះនៅសាលាដំបូង ឬសាលាឧទ្ធរណ៍បានឡើយ បើពុំដូច្នោះទេសេចក្តីសម្រេចនោះ ត្រូវទុកជាមោឃៈ។

មាត្រា៨១..

ចៅក្រមទាំងឡាយដែលមានសហព័ន្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ ថ្នាក់៤ (បួន) រាប់ទាំងថ្នាក់ទី៤(បួន)ផង ធ្វើជាមេធាវីក្នុងរឿងក្តីឲ្យគូភាគីណាមួយមិនអាចចូលជំនុំជម្រះរឿងក្តីនោះនៅសាលាដំបូង ឬសាលាជាន់ខ្ពស់ណាមួយបានឡើយ បើពុំដូច្នោះទេ សេចក្តីសម្រេចនោះត្រូវទុកជាមោឃៈ។

មាត្រា ៨២..

ភាគីទាំងឡាយនៅក្នុងរឿងក្តី រួមទាំងអយ្យការផង អាចប្តឹងសុំមោឃភាពចំពោះសេចក្តីសម្រេចរបស់តុលាការ ដោយមូលហេតុបំពានវិធានស្តីពីវិសមិតភាពដូចដែលមានចែងនៅក្នុងបទបញ្ញត្តិនៃមាត្រា ១២០ និងមាត្រា ១២១នៃច្បាប់នេះ។ បណ្តឹងសុំមោឃភាពនេះ ត្រូវ ធ្វើឡើងនៅក្នុងរយៈពេល នៃបណ្តឹងទាស់ឬបណ្តឹងឧបាស្រ័យ។

## ជំពូកទី៧
## ការត្រួតពិនិត្យសាលាជម្រះក្តី

មាត្រា ៨៣..

រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ត្រូវពិនិត្យលើដំណើរការ ផ្នែករដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់តាមរយៈអគ្គាធិការដ្ឋានកិច្ចការតុលាការនៃក្រសួងយុត្តិធម៌។

មាត្រា៨៤..

ក្នុងករណីចាំបាច់រដ្ឋមន្រ្តីក្រសួយុត្តិធម៌អាចធ្វើអធិការកិច្ចលើបញ្ហាណាមួយ ជាកំណត់រួចធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ (អង្គប្រជុំយល់ថាគួរដាក់ច្បាប់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម)

## ជំពូកទី៨

# អន្តរប្បញ្ញត្តិ

មាត្រា ៨៥..

មុខងារជំនុំជម្រះ និងមុខងារស៊ើបសួរត្រូវបែងចែកដាច់ពីគ្នា នៅពេលដែលមានចៅក្រមគ្រប់គ្រាន់។

មាត្រា ៨៦..

នៅពេលដែលមិនទាន់មានច្បាប់ស្តីពីនីតិវិធីរដ្ឋបាល នីតិវិធីពាណិជ្ជកម្ម និងនិតិវិធីការងារ និងសន្តិសុខសង្គម និតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះរឿងក្តីដែលជំនុំជម្រះដោយសភារដ្ឋបាល សភាពាណិជ្ជកម្ម សភាការងារ និងសន្តសុខសង្គម និងសភាអនីតិជននៃតុលាការគ្រប់ជាន់ថ្នាក់។

មាត្រា ៨៧..

កាលបើសភាណាមួយ ពុំអាចបង្កើតឲ្យដំណើរការបាននៅក្នុងសាលាដំបូងណាមួយដោយហេតុថាពុំមានចៅក្រមគ្រប់គ្រាន់ ឬកាលបើសភានោះត្រូវបានបង្កើតឡើង ហើយតែពុំអាចដំណើរការបាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាស ដើម្បីគូសបញ្ជាក់អំពីនត្តិភាពនៃសភានោះតាមសំណើរបស់ប្រធានសាលាដំបូងសាមី។

ប្រសិនបើពុំមានសភាពាណិជ្ជកម្ម សភារដ្ឋបាល ឬសភាការងារ និងសន្តិសុខសង្គមនៅក្នុងសាលាដំបូងណាមួយ ឬសភាទាំងនោះដែលបង្កើតឡើងហើយ តែពុំទាន់អាចដំណើរការបានទេ នោះសំណុំរឿងវិវាទក្នុងរឿងរដ្ឋបាល រឿងពាណិជ្ជកម្ម ឬរឿងការងារ និងសន្តិសុខសង្គមត្រូវបញ្ជូនទៅសភារដ្ឋប្បវេណីនៃសាលាដំបូង។

ផ្ទុយទៅវិញកាលណាមានបទបញ្ញត្តិថ្មី កំណត់អំពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ឬសភាជំនាញណាមួយរួចហើយ តុលាការ ឬសភាជំនាញផ្សេងទៀតត្រូវផ្ទេរជាស្វ័យប្រវត្តិនូវសំណុំរឿងដែលមិនទាន់ចាត់ការជូនទៅតុលាការ ឬសភាជំនាញដែលមានសមត្ថកិច្ចនោះ។

នៅក្នុងដំណាក់កាលកម្ពុជាពុំទាន់មានចៅក្រមគ្រប់គ្រាន់ សម្រាប់បង្កើតសភាទាំងអស់នៅក្នុងតុលាការគ្រប់ជាន់ថ្នាក់ តាមចំនួនកំណត់ចាំបាច់សម្រាប់សភានីមួយៗនៅឡើយទេ ចៅក្រមអាចធ្វើជាសមាជិកនៃសភាច្រើនបាន។

## ជំពូក ទី៩

# អវសានប្បញ្ញត្តិ

មាត្រា ៨៨..

បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។